សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ
និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

# កិច្ចការស្រាវជ្រាវ

# អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ
( IJM )


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ

**-កែ ហុកស្រ៊ុន** **-នុត វណ្ណះ**

**-សួរ ចំណាប់** **-សេង សុគន្ធា**

សាស្ត្រាចារ្យណែនាំ

លោក **ម៉ៅ មុន្នីរ៉ា**



ថ្នាក់ **បរិញ្ញាបត្រជាន់ខ្ពស់ នីតិសាស្ត្រ** ឆ្នាំចូលសិក្សា ២០១៣

ជំនាញ **នីតិឯកជន** ជំនាន់ទី១០ ឆ្នាំសរសេរកិច្ចការស្រាវជ្រាវ ២០១៤



**រក្សាសិទ្ធិដោយ** Khmer Famous

# អារម្ភកថា

មនុស្សរស់នៅក្នុងសង្គមតែងតែចង់បានសិទ្ធិសេរីភាពក្នុងការរស់នៅ ភាពរីកចម្រើន និង សុភមង្គល ។ ដើម្បីទទួលបានបំណងប្រាថ្នាទាំងអស់នេះ ពិភពលោកចាំបាច់ត្រូវធ្វើច្បាប់ សាកល ភាវូបនីយកម្ម ដែលបើកឱកាសឲ្យមានការវិនិយោគ ក៏ដូចជាការបណ្តុះបណ្តាល ទេសចរណ៍ និង ជំនួញផ្សេងៗទៀត ។ ទន្ទឹមនឹងនេះ ជនល្មើសក៏ឆ្លៀតយកឱកាសនេះដើម្បីកេង យកប្រយោជន៍ពីជនដែលងាយរងគ្រោះ ជាពិសេសស្ត្រី និងកុមារ ។ ដើម្បីធានាថា ច្បាប់ត្រូវបាន អនុវត្តប្រកបដោយប្រសិទ្ធភាពក្នុងការប្រឆាំងនឹងឧក្រិដ្ឋកម្មនានា ដែលបង្កឡើងដោយឧក្រិដ្ឋជន រដ្ឋាភិបាល ក៏ដូចជាអង្គការនានា ថ្នាក់ជាតិ និងអន្តរជាតិត្រូវសហការគ្នា និងធ្វើការដើម្បីផ្តល់ សុវត្ថិភាពគ្រប់យ៉ាងដល់ប្រជាជន និងការអភិវឌ្ឍប្រទេសជាតិ ។

តើមានអង្គការអន្តរជាតិណាខ្លះដែលធ្វើការសហការជាមួយអាជ្ញាធរក្នុងស្រុក ដើម្បីប្រយុទ្ធ ប្រឆាំងនឹងឧក្រិដ្ឋកម្ម ជាពិសេសអំពើជួញដូរមនុស្ស ដែលជាបទឧក្រិដ្ឋបំផ្លាញដល់ដួងព្រលឹង របស់មនុស្សជាតិ?

អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិគឺជាទីភ្នាក់ងារមនុស្សធម៌ដែលធ្វើការដោយផ្ទាល់ជាមួយ អាជ្ញារក្នុងស្រុក ទូទាំងពិភពលោកដើម្បីធ្វើឲ្យមានប្រព័ន្ធយុត្តិធម៌មួយដែលពិតជាការពារដល់ផល ប្រយោជន៍ និងសុវត្ថិភាពរបស់ប្រជាជន ។

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតជូនចំពោះលោកឪពុក អ្នកម្តាយដែលបានផ្តល់ជីវិត និងបីបាច់ថែរក្សាយើងខ្ញុំ ជារៀងរហូតមក ព្រមទាំងផ្គត់ផ្គង់ការសិក្សាតាំងពីថ្នាក់មត្តេយ្យរហូតដល់ថ្នាក់ឧត្តមសិក្សា ។ ដោយសារគុណូបការៈរបស់លោកអ្នកមានគុណទាំងពីរ ទើបធ្វើឲ្យយើងខ្ញុំបានរៀនសូត្រ និងមានចំណេះវិជ្ជារហូតដល់បច្ចុប្បន្ន ។

ទន្ទឹមនឹងនេះដែរ យើងខ្ញុំក៏សូមសម្តែងនូវអំណរគុណ ចំពោះលោកគ្រូ អ្នកគ្រូ ព្រមទាំងសាស្ត្រាចារ្យទាំងអស់ ដែលបានលះបង់កម្លាំងកាយ កម្លាំងចិត្ត និងពេលវេលាដ៏មានតម្លៃ ជួយបង្ហាត់បង្ហាញ និងផ្តល់ចំណេះដឹងដល់យើងខ្ញុំតាំងពីវ័យកុមារ រហូតដល់បច្ចុប្បន្ន ។ ដោយសារគុណូបការៈរបស់លោកអ្នកទាំងអស់នេះហើយ ទើបយើងខ្ញុំមានចំណេះដឹងអាចធ្វើការសិក្សាស្រាវជ្រាវ ស្វែងយល់ពីបញ្ហានានានៅក្នុងសង្គម មានវិជ្ជាជីវៈសម្រាប់ចិញ្ចឹមជីវិត ក្លាយជាពលរដ្ឋល្អ និងចូលរួមអភិវឌ្ឍប្រទេសជាតិឲ្យបានរីកចម្រើន ។

លើសពីនេះទៅទៀត យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ដល់លោកសាស្ត្រាចារ្យ **មៅ ប៊ុណ្ណា** ដែលបានលះបង់ពេលវេលាដ៏មានតម្លៃក្នុងការបង្ហាត់បង្ហាញ ផ្តល់គំនិតសម្រាប់ធ្វើការស្រាវជ្រាវ ក៏ដូចជាការផ្តល់ដំបូន្មាន នៅក្នុងថ្នាក់រៀន ផងដែរ ។

យើងខ្ញុំសូមគោរពជូនពរដល់លោកអ្នកមានគុណទាំងអស់ ឲ្យជួបប្រទះតែសេចក្តីសុខ សេចក្តីចម្រើនគ្រប់ពេលវេលា ។

# មាតិកា

ទំព័រ


ប្រវត្តិសង្ខេប .................... ០១
អត្តសញ្ញាណ .................... ០៣
រចនាសម្ព័ន្ធ .................... ០៤
គណៈគ្រប់គ្រង .................... ០៦
ការចារជាសារវ័ន្ត .................... ០៦
គតិយុត្តិ .................... ០៧
កំណត់ទិសដៅទៅថ្ងៃមុខ.................... ០៧
បេសកកម្ម .................... ០៨
ចក្ខុវិស័យ .................... ០៨
គោលបំណង និងសកម្មភាព.................... ០៩
១. ទាសភាព .................... ០៩
២. ការជួញដូរផ្លូវភេទ .................... ១១
៣. អំពើហិង្សាផ្លូវភេទ .................... ១៣
៤. ការរឹបអូសយកទ្រព្យសម្បត្តិ .................... ១៥
៥. ការរំលោភបំពានអំណាចរបស់ប៉ូលិស .................... ១៧
៦. ការរំលោភបំពានសិទ្ធិប្រជាពលរដ្ឋ .................... ១៨
សេចក្តីសន្និដ្ឋាន
អនុសាសន៍
ឯកសារយោង

# ប្រវត្តិសង្ខេប

អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ ត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ ១៩៩៧ ដោយលោក ហ្គែរី ហូហ្គិន (Gary Haugen) ដែលជាមេធាវីផ្នែកសិទ្ធិមនុស្សធ្វើការនៅក្នុងនាយកដ្ឋានយុត្តិធម៌សហរដ្ឋអាម៉េរិក ។ លោកធ្លាប់បានធ្វើការជាប្រធានផ្នែកស៊ើបអង្កេតរបស់អង្គការសហប្រជាជាតិ បន្ទាប់ពីការសម្លាប់រង្គាលជនជាតិរវ៉ាន់ដា (Rwanda) ។ លោក ហូហ្គិន ធ្លាប់បានធ្វើការសិក្សាស្រាវជ្រាវទៅលើភាពអយុត្តិធម៌ដែលទទួលរងគ្រោះដោយបុគ្គលិកផ្នែកជំនួយ អភិវឌ្ឍន៍ និង បេសកកម្ម ។ ដោយធ្វើការវាស់ស្ទង់មតិជាង ៦៥ អង្គការ និងដោយតំណាងបុគ្គលិក ៤០ ០០០ នាក់ ការសិក្សាស្រាវជ្រាវនេះបានបង្ហាញនូវការយល់ដឹងជាឯកឆន្ទស្តីពីការបំពានអំណាច ដោយហិង្សា ដែលប្រព្រឹត្តឡើងដោយប៉ូលិស និងអាជ្ញាធរផ្សេងទៀតនៅក្នុងសហគមន៍ដែលជាអ្នកការពារបម្រើប្រជាជន ។

បញ្ហាទាំងនោះហាក់ដូចជាធំសម្បើមនិងមិនអាចធ្វើបាន ។ ប៉ុន្តែលោក ហូហ្គិននិងក្រុមការងារតូចមួយបានរៀបចំគម្រោងផែនការដោយមាន អ្នកស៊ើបអង្កេត មេធាវី និងបុគ្គលិកសង្គមកិច្ច ចូលរួមបង្ហាញនូវជំនាញពិសេសរបស់ពួកគេដើម្បីធ្វើការជាមួយប្រព័ន្ធយុត្តិធម៌សាធារណៈដែលបាក់បែកមិនអាចការពារជនក្រីក្របាន ។ នៅក្នុងរយៈពេលជាង ១៥ ឆ្នាំ បន្ទាប់ពីការបង្កើតអង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ អង្គការនេះបាននាំមកនូវការសង្គ្រោះជនរងគ្រោះរាប់ពាន់នាក់ ។ លើសពីនេះទៅទៀត អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិបានរីកចម្រើនទាំងបុគ្គលិកធ្វើការរហូតមានច្រើនជាង ៦០០ នាក់ ដែលក្នុង ៩៥% គឺជាបុគ្គលិកជាតិនៃប្រទេសដែលពួកគេធ្វើការ ។

អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិគឺជាទីភ្នាក់ងារសិទ្ធិមនុស្សជាសាកលមួយ ដែលមានវត្តមានរយៈពេលវែងនៅក្នុងប្រទេស ១៦ នៅទូទាំងពិភពលោក និងមានការិយាល័យគាំទ្រនៅសហរដ្ឋអាម៉េរិក កាណាដា និងអឺរ៉ុប ។ អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិបានធ្វើការជួយសង្គ្រោះជនរងគ្រោះដោយទាសភាព ដោយការកេងប្រវ័ញ្ចផ្លូវភេទ និងទម្រង់នៃការគាបសង្កត់ដោយអំពើហិង្សាផ្សេងទៀត ។ អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិបានធ្វើការស៊ើបអង្កេត និងចងក្រងឯកសារនូវករណីនានាអំពីអំពើធ្វើអាជីវកម្មផ្លូវភេទលើអនីតិជននៅកម្ពុជា តាំងពីឆ្នាំ ២០០០ និងបានបើកការិយាល័យជាផ្លូវការរបស់ខ្លួនប្រចាំនៅកម្ពុជា នៅទីក្រុងភ្នំពេញ នាខែមីនា ឆ្នាំ ២០០៤ ។

អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិគឺជាទីភ្នាក់ងារសិទ្ធិមនុស្សមិនរកប្រាក់ចំណូល ដែលមានមូលដ្ឋានធំនៅទីក្រុងវ៉ាស៊ីងតោន សហរដ្ឋអាម៉េរិក ។ អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិធ្វើការជួយសង្គ្រោះជនរងគ្រោះដោយអំពើទាសភាព ដោយការកេងប្រវ័ញ្ចផ្លូវភេទ និងទម្រង់នៃការគាបសង្កត់ដោយអំពើហិង្សាផ្សេងទៀត ។ បុគ្គលិករបស់អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិមានអ្នកអាជីពជាមេធាវី អ្នកស៊ើបអង្កេត និងបុគ្គលិកសង្គមកិច្ច ដែលធ្វើការជាមួយមន្ត្រីអនុវត្តន៍ច្បាប់ក្នុងស្រុកនៃប្រទេសនីមួយៗ ដើម្បីផ្តល់នូវការជួយសង្គ្រោះនិងការថែទាំដល់ជនរងគ្រោះ ធ្វើការចោទប្រកាន់ចំពោះជនល្មើស និងធានាថាប្រព័ន្ធយុត្តិធម៌សាធារណៈ ដែលមានមន្ត្រីអនុវត្តន៍ច្បាប់ស្ថាប័នអយ្យការ ស្ថាប័នតុលាការ និងមន្ត្រីសង្គមកិច្ច ការពារជនក្រីក្រប្រកបដោយប្រសិទ្ធភាព ។

**អត្តសញ្ញាណ**

ឈ្មោះពេញ៖ អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ (International Justice Mission)

អក្សរកាត់៖ អ.ប.យ.អ (IJM)

ប្រធាន៖ លោក ហ្គែរី ហូហ្គិន (Gary Haugen)

រូបតំណាង (Logo)៖

ក្របខ័ណ្ឌ៖ ជាអង្គការស្វយ័ត

ទីតាំង៖ មូលដ្ឋានធំនៅទីក្រុងវ៉ាស៊ីងតោន សហរដ្ឋអាមេរិក

ការិយាល័យមាន ១៦ ៖ នៅក្នុងប្រទេស ហ្គាតឺម៉ាឡា (Guatemala) បូលីវីយ៉ា(Bolivia) សាធារណរដ្ឋដូមីនីកែន(Dominican Republic) ថៃឡង់(Thailand) កម្ពុជា(Cambodia) ហ្វីលីពីន (The Philippines) កេនយ៉ា (Kenya) យូហ្កង់ដា(Uganda) ហ្សាមប៊ីយ៉ា(Zambia) រវ៉ាន់ដា (Rwanda) ឥណ្ឌា (India)។

ការិយាល័យធ្វើការជាដៃគូមាន ៧៖ នៅក្នុងប្រទេសកាណាដា(Canada) នីដឺឡែន(Netherland) អាឡឺម៉ង់ (Germany) និងចក្រភពអង់គ្លេស(the United Kingdom) អេខ្វាដ័រ(Ecuador) ប៉េរ៉ូ (Peru) និងអូស្រ្តាលី (Australia)



កាលបរិច្ឆេទបង្កើត៖ ឆ្នាំ ១៩៩៧

មូលហេតុ៖ ដើម្បីការពារជនក្រីក្រពីអំពើហិង្សា ដោយធ្វើការសហការជាមួយអាជ្ញាធរមូលដ្ឋានដើម្បី ជួយសង្គ្រោះជនរងគ្រោះ កាត់ទោសជនល្មើស ស្តារនីតិសម្បទាដល់ជនរងគ្រោះ និងពង្រឹងប្រព័ន្ធយុត្តិធម៌ និងឆ្លើយតបចំពោះសេចក្តីស្រឡាញ់ពីព្រះយេស៊ូ ។

ថវិកា៖ ២៤.៦ លានដុល្លារអាម៉េរិក (ឆ្នាំ ២០១០)

វិបសាយ៖ ijm.org

ចំនួនសមាជិក៖ ច្រើនជាង ៦០០ នាក់ ទូទាំងពិភពលោក

## រចនាសម្ព័ន្ធ៖

- លោក Gary Haugen គឺជាអ្នកបង្កើតនិងជាប្រធាននៃអង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ ។
- លោក Gary Veurink គឺជាអនុប្រធានប្រតិបត្តិ និងប្រធានមន្ត្រីប្រតិបត្តិការ ។
- លោកស្រី Chong-Ae Shah គឺជាអនុប្រធានផ្នែកទីផ្សារម៉ាកសាកលនិងការបង្រួបបង្រួម ។ លោកស្រី Chong-Ae ទទួលខុសត្រូវសម្រាប់ការអភិវឌ្ឍម៉ាកសាកល និងរៀបចំយុទ្ធសាស្ត្រការបង្រួបបង្រួម ទំនាក់ទំនងរដ្ឋាភិបាល និងការតស៊ូមតិ យុទ្ធសាស្ត្រសម្រាប់ភាពជាដៃគូ និងទំនាក់ទំនងសាធារណៈនិងទីផ្សារពិភពលោក ។
- លោក Sean Litton គឺជាអនុប្រធានជាន់ខ្ពស់ផ្នែកប្រតិបត្តិការយុត្តិធម៌ ។ លោក Sean ដឹកនាំប្រតិបត្តិការសាកលនៅក្នុងតំបន់អាហ្វ្រិក អាម៉េរិកឡាទីន អាស៊ីខាងត្បូង និងអាស៊ីអាគ្នេយ៍ ។
- លោកស្រី Sharon Cohn Wu គឺជាអនុប្រធានជាន់ខ្ពស់ផ្នែកកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ ។
- លោក Holly J. Burkhalter គឺជាអនុប្រធានផ្នែកទំនាក់ទំនងរដ្ឋាភិបាល និងការតស៊ូមតិ ។
- លោក Bill Clark គឺជាអនុប្រធានផ្នែកបង្រួបបង្រួម រៀបចំយុទ្ធសាស្ត្រ និងគំនិតផ្តួចផ្តើមដើម្បីបង្កើនចលនាយុត្តិធម៌ ។

- លោក Blair Burns គឺជាអនុប្រធានផ្នែកប្រតិបត្តិការសម្រាប់អាស៊ីអាគ្នេយ៍ ។
- លោក Mark Clookie គឺជាអនុប្រធានផ្នែកស៊ើបអង្កេត និងការអភិវឌ្ឍមន្ត្រីអនុវត្តន៍ច្បាប់ ។
- លោក John Lax គឺជាអនុប្រធានផ្នែកប្រព័ន្ធព័ត៌មាន ។ លោក ទទួលខុសត្រូវរៀបចំផែនការជាយុទ្ធសាស្ត្រសម្រាប់ការបញ្ចូលនូវធនធានសាកលដើម្បីបំពេញតម្រូវការចាំបាច់ផ្នែកព័ត៌មាន និងការរៀបចំប្រព័ន្ធអ៊ិនធឺណេត និងបច្ចេកទេស ។
- លោក Jim Martin គឺជាអនុប្រធានផ្នែកសាសនាគ្រឹស្ត ។
- លោកស្រី Sheeba Philip គឺជាអនុប្រធានផ្នែកទីផ្សារសាកលនិងទំនាក់ទំនងសាធារណៈ ។
- លោកស្រី Melissa Russell គឺជាអនុប្រធានផ្នែកយុទ្ធសាស្ត្រនៃភាពជាដៃគូ ។
- លោកស្រី Kathy Stout-LaBauve គឺជាអនុប្រធានផ្នែកថែទាំ ។
- លោក Pablo Villeda គឺជាអនុប្រធានប្រតិបត្តិការសម្រាប់តំបន់អាម៉េរិកឡាទីន ។
- លោក Philip Langford គឺជាអនុប្រធានប្រតិបត្តិការសម្រាប់តំបន់អាហ្វ្រិក ។
- លោក Saju Mathew គឺជាអនុប្រធានប្រតិបត្តិការសម្រាប់តំបន់អាស៊ីខាងត្បូង ។
- លោកស្រី Shelley Thames គឺជាទីប្រឹក្សាជាន់ខ្ពស់ ដោយផ្តល់នូវភាពជាអ្នកដឹកនាំប្រតិបត្តិនៅក្នុងការអភិវឌ្ឍគម្រោង ផែនការជាយុទ្ធសាស្ត្រនិងរចនាសម្ព័ន្ធ ។
- លោកស្រី Lauren Weaver គឺជាអនុប្រធានផ្នែកហិរញ្ញវត្ថុ ។
- លោក Tony Webster គឺជាអនុប្រធានផ្នែកធនធានមនុស្ស ។
- លោក Eric Ha គឺជាអគ្គមេធាវី ដោយផ្តល់នូវគោលការណ៍ណែនាំជាយុទ្ធសាស្ត្រដើម្បីធ្វើឲ្យអង្គការ IJM អនុវត្តបាននូវបេសកកម្មរបស់ខ្លួនដោយអនុលោមតាមច្បាប់ជាធរមាន ។

## គណៈគ្រប់គ្រង

**Eric Asche**
*Chief Marketing Officer, Legacy*

**Nicole Bibbins Sedaca | Board Chair**
*Director of the DC office of Independent Diplomat*

**Rebecca Chan**
*Professor, Tsinghua University School of Law*

**Ram Gidoomal**
*Independent Social Entrepreneur*

**Gary Haugen**
*President & CEO*

**Paul Lee**
*Senior Product Manager, Google.org*

**Laurent Mbanda**
*Bishop of the Anglican Church of Rwanda, Shyira Diocese*

**Terry Mochar**
*Founder and President, Mochar International Management Ltd.*

**Nancy Ortberg**
*Director of Leadership Development, Menlo Park Presbyterian Church*

**Raj Parker**
*Partner, Freshfields Brukhaus Deringer LLP*

**Nicholas Sensley**
*CEO of Cross Sector Solutions LLC.*

**Patty Sison-Arroyo**
*Professor at Ateneo Law School in Manila, Philippines*

**Alfonso Wieland**
*Co-founder and Executive Director, Paz y Esperanza*

**Martin Witteveen**
*Magistrate, District Court of the Hague*

## ការងារជាសារវ័ន្ត

- **ជួយសង្គ្រោះជនរងគ្រោះ**

ធ្វើការជាដៃគូសហការជាមួយមន្រ្តីអនុវត្តន៍ច្បាប់ក្នុងស្រុក ដើម្បីធ្វើប្រតិបត្តិការជួយសង្គ្រោះជនរងគ្រោះ ហើយធានាឲ្យជនរងគ្រោះនីមួយៗបានរួចខ្លួនដោយស្របច្បាប់ និងទទួលបានការគាំទ្រក៏ដូចជាការស្តារនីតិសម្បទាពីអង្គការជាដៃគូ ឬរដ្ឋាភិបាល ។

- **ការនាំយកឧក្រិដ្ឋជនឲ្យទទួលទោសតាមច្បាប់**

គាំទ្រដល់របាយការណ៍ប៉ូលិសដើម្បីប្តឹងម្ចាស់បំណុល ឧក្រិដ្ឋជន ឬជនល្មើសជួញដូរមនុស្ស និងគាំទ្រឲ្យមានការកាត់ទោសដល់ជនល្មើសទាំងនោះ ។

- **ការស្តារនីតិសម្បទាដល់ជនរងគ្រោះ**

បង្កើតផែនការថែទាំដល់បុគ្គលនីមួយៗ ដើម្បីឆ្លើយតបនឹងការប៉ះទង្គិចផ្លូវចិត្ត និងស្វែងរកការងារសមរម្យ និងផ្តល់ឱកាសឲ្យទទួលបានការអប់រំនិងការបណ្តុះបណ្តាលវិជ្ជាជីវៈ ។

- **ការពង្រឹងប្រព័ន្ធយុត្តិធម៌**

ផ្តល់នូវការងារដឹកនាំជាគំរូសម្រាប់មន្ត្រីអនុវត្តន៍ច្បាប់ មន្ត្រីរដ្ឋាភិបាល និងអង្គការជាដៃគូ ។ បង្កើតផងដែរនូវតម្រូវការសង្គម និងការតស៊ូមតិជាមួយថ្នាក់ដឹកនាំជាតិ ដើម្បីបញ្ឈប់ទាសភាពអំពើជួញដូរមនុស្សដែលជាការងារអាទិភាព ។

## ការធ្វើមហាសន្និបាត ៖

បុគ្គលិក IJM បានចូលរួមចែករំលែកនូវរឿងរ៉ាវនៃភាពអយុត្តិធម៌ ការជួយសង្គ្រោះនិងការស្តារនីតិសម្បទា ។ មានអ្នកចូលរួម ១៣០០ នាក់ មកពីប្រទេសជាច្រើនទូទាំងពិភពលោកនៅក្នុងព្រឹត្តិការណ៍ដ៏អស្ចារ្យជារៀងរាល់ឆ្នាំ ដើម្បីជួយអធិដ្ឋាន ក៏ដូចជាគាំទ្រសម្រាប់កុមារ ស្ត្រី និងបុរសដែលជាប់អន្ទាក់នៅក្នុងភាពងងឹតនិងទីកន្លែងហិង្សា ។ ព្រឹត្តិការណ៍នេះនឹងត្រូវធ្វើម្តងទៀតពីថ្ងៃទី ១៦-១៨ មេសា ២០១៥ ។ អ្នកអាចចុះឈ្មោះបានតាមវ៉ិបសាយ http://www.ijm.org/GPG

## គតិយុត្តិ

អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិគឺជាទីភ្នាក់ងារសិទ្ធិមនុស្សមិនរកប្រាក់ចំណូល ដែលមានមូលដ្ឋានធំនៅទីក្រុងវ៉ាស៊ីនតោន សហរដ្ឋអាម៉េរិក និងមានការិយាល័យរបស់ខ្លួនក្នុង ១៨ ប្រទេស ។ អង្គការ IJM បានចុះអនុស្សរណៈនៃការយោគយល់គ្នាជាមួយក្រសួងការបរទេស និងកិច្ចសហប្រតិបត្តិការអន្តរជាតិ នៃព្រះរាជាណាចក្រកម្ពុជា តាំងពីឆ្នាំ ២០០៣ និងជាមួយក្រសួងមហាផ្ទៃ និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ។

## កំណត់ទិសដៅនៅថ្ងៃមុខ

អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិនឹងពង្រីកការិយាល័យរបស់ខ្លួន ឲ្យបានដល់ ២៥ ការិយាល័យនៅក្នុងទីក្រុងដែលមានប្រជាជនរស់នៅច្រើន នៃប្រទេសកំពុងអភិវឌ្ឍន៍ ដែលមានការងាររៀបចំរឿងក្តីរបស់ខ្លួនជាច្រើនដែលអាចធ្វើបាន និងមានសក្តានុពលធ្វើឲ្យមានការផ្លាស់ប្តូរនៅក្នុងប្រព័ន្ធយុត្តិធម៌សាធារណៈក្នុងឆ្នាំ ២០១៧ ។

## បេសកកម្ម

ការពារប្រជាជនក្រីក្រពីអំពើហិង្សា ដោយផ្តល់នូវការជួយសង្គ្រោះ និងការស្តារនីតិសម្បទាសម្រាប់ជនរងគ្រោះ ឲ្យទទួលបាននូវសុវត្ថិភាព និងភាពរឹងប៉ឹង នាំយកឧក្រិដ្ឋជនឲ្យទទួលខុសត្រូវចំពោះមុខច្បាប់ និងជួយដល់មន្ត្រីអនុវត្តន៍ច្បាប់ក្នុងស្រុកកសាងនូវអនាគតដែលមានសុវត្ថិភាពដ៏យូរអង្វែង ។

## ចក្ខុវិស័យ

នៅក្នុងពិភពលោកដែលត្រូវបំផ្លាញដោយភាពអយុត្តិធម៌និងអំពើហិង្សា ដែលធ្វើឡើងចំពោះប្រជាជានក្រីក្រ អង្គការ IJM នឹងធ្វើការបំផុសឲ្យមានចលនាបង្រួបបង្រួមអ្នកដឹកនាំគ្រីស្តបរិស័ទក្នុងរយៈពេល ១០ឆ្នាំខាងមុខ ដែលនឹងជួយសង្គ្រោះនិងស្តារនីតិសម្បទាដល់ជីវិតបុគ្គលរាប់ពាន់នាក់ ការពារសហគមន៍ និងផ្លាស់ប្តូរទស្សនៈវិស័យរបស់ពិភពលោកចំពោះអ្វីដែលអាចធ្វើបាន ។

ប្រជាជនក្រីក្ររាប់រយលាននាក់នៅក្នុងប្រទេសកំពុងអភិវឌ្ឍ ត្រូវបានជាប់អន្ទាក់ដោយភាពអស់សង្ឃឹមនៅក្នុងទីជម្រៅនៃភាពអយុត្តិធម៌ដែលប្រើអំពើហិង្សា ពីព្រោះតែច្បាប់ជាមូលដ្ឋានដែលបង្កើតឡើងដើម្បីការពារពួកគេមិនត្រូវបានគេអនុវត្តឲ្យមានប្រសិទ្ធភាព ។ ដោយគ្មានការការពារ ប្រជាជនក្រីក្រដឹងថាអនាគតរបស់ខ្លួនត្រូវបានលួចប្លន់ដោយអំពើហិង្សាផ្លូវភេទ ការរំលោភបំពានដោយប៉ូលិស ការឃុំខ្លួនមិនស្របច្បាប់ ពលកម្មដោយបង្ខំ និងការរឹបអូសយកដីធ្លីដែលមិនអាចទប់ទល់បាន ។

លើសពីនេះ ដោយគ្មានសង្ឃឹមនឹងទទួលបានការការពារពីប្រព័ន្ធយុត្តិធម៌ នៅក្នុងពិភពលោកដែលកំពុងអភិវឌ្ឍ ប្រជាជនទាំងនោះក៏បាត់បង់នូវក្តីសង្ឃឹមផងដែរថាគ្មាននរណាម្នាក់អាចជួយជនរងគ្រោះដែលគេធ្វើបាបនោះឡើយ ។

ក្នុងរយៈពេល ១០ ឆ្នាំខាងមុខ អង្គការ IJM នឹងស្វះស្វែងដើម្បីស្តារនូវក្តីសង្ឃឹមសម្រាប់ប្រជាជនក្រីក្រនិងជនរងគ្រោះ ដោយជួយសង្គ្រោះជនរងគ្រោះរាប់ពាន់នាក់ និងបង្ហាញថា វាមានលទ្ធភាពដើម្បីធ្វើឲ្យប្រព័ន្ធយុត្តិធម៌សាធារណៈពិតជាដំណើរការសម្រាប់ប្រជាជនក្រីក្រី ។

ក្នុងរយៈពេល ១០ ឆ្នាំខាងមុខ អង្គការ IJM នឹងស្វះស្វែងរកនូវយុត្តិធម៌សម្រាប់ប្រជាជន

ក្រីក្រ តាមរយៈប្រព័ន្ធយុត្តិធម៌សាធារណៈដែលមានការផ្លាស់ប្តូរ ។ ប៉ុន្តែតាមរយៈការងាររៀបចំរឿងក្តីរបស់ខ្លួន អង្គការ IJM នឹងបញ្ជាក់ថា ការផ្លាស់ប្តូរប្រព័ន្ធបែបនោះគឺពិតជាមាននៅពេលដែលទទួលបានលទ្ធផលល្អនៅក្នុងការផ្លាស់ប្តូររបស់ខ្លួន ។

ដោយការផ្តល់អំណាច និងភាពជាអ្នកដឹកនាំដល់បុគ្គលិកជាតិជាគ្រឹស្តបរិស័ទអាជីពធនធាន និងការបណ្តុះបណ្តាលចាំបាច់ដើម្បីធ្វើការងាររៀបចំរឿងក្តីឲ្យមានប្រសិទ្ធភាព នៅក្នុងឆ្នាំ ២០១៧ ដោយសង្គ្រោះ និងស្តារនីតិសម្បទាជនរងគ្រោះប្រហែល ៣០០០ នាក់ និងនាំយកជនល្មើសនៃអំពើហិង្សាប្រហែល ៥០០ នាក់ឲ្យទទួលខុសត្រូវចំពោះមុខច្បាប់ ។

## គោលបំណង និងសកម្មភាព

ការពារប្រជាជនក្រីក្រពីអំពើហិង្សា ដោយផ្តល់នូវការជួយសង្គ្រោះ និងការស្តារនីតិសម្បទាសម្រាប់ជនរងគ្រោះ ឲ្យទទួលបាននូវសុវត្ថិភាព និងភាពរឹងប៉ឹង នាំយកឧក្រិដ្ឋជនឲ្យទទួលខុសត្រូវចំពោះមុខច្បាប់ និងជួយដល់មន្ត្រីអនុវត្តន៍ច្បាប់ក្នុងស្រុកកសាងនូវអនាគតដែលមានសុវត្ថិភាពដ៏យូរអង្វែង ។

ការិយាល័យតាមតំបន់របស់អង្គការ IJM មានកម្មវិធីកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ ដែលផ្តោតលើអំពើហិង្សារៀងរាល់ថ្ងៃ ដូចខាងក្រោម៖

### ១. ទាសភាព

- ទាសភាពពលកម្មដោយបង្ខំប្រើប្រាស់ ការឆបោក ការគំរាមកំហែងឬអំពើហិង្សាដោយបង្ខំនរណាម្នាក់ឲ្យធ្វើការដោយឲ្យកម្រៃតិចតួចឬមិនឲ្យកម្រៃ ។ ទោះបីជាទាសភាពគឺជាបញ្ហាខុសច្បាប់នៅស្ទើរតែគ្រប់ប្រទេសក៏ដោយ ក៏មានបុរស ស្ត្រី និងកុមាររាប់លាននាក់កំពុងធ្វើការជាទាសករនៅក្នុងឡឥដ្ឋ រោងម៉ាស៊ីនកិនស្រូវ រោងចក្រកាត់ដេរ ការនេសាទ និងឧស្សាហកម្មផ្សេងៗទៀត ។
- សព្វថ្ងៃ មានមនុស្សប្រហែលជា ២៩.៨ លាននាក់ ត្រូវបានគ្រប់គ្រងសម្រាប់ទាសភាព (លិបិក្រមនៃទាសភាពសាកល ២០១៣)
- ជនរងគ្រោះដែលទទួលរងនូវពលកម្មដោយបង្ខំ មានកុមារប្រហែល ២៦ % ។ (អង្គការ ILO: សង្ខេបពីពលកម្មដោយបង្ខំ ២០១២)

- ប្រទេសឥណ្ឌាមានចំនួនប្រជាជនដ៏ច្រើនជាងគេ ដែលស្ថិតនៅក្នុងទាសភាពប្រហែលពី១៣,៣ លាន ទៅ ១៤, ៧ លាននាក់ ។ (លិបិក្រមនៃទាសភាពសាកល ២០១៣៖ឥណ្ឌា)

ទាសភាពពលកម្មដោយបង្ខំគឺជាឧក្រិដ្ឋកម្មហិង្សា ។ ការរំលោភខាងផ្លូវភេទនិងរាងកាយកើតមានជាហូរហែ ។ នៅក្នុងករណីរឿងក្ដីរបស់ អង្គការ IJM យើងបានចងក្រងជាឯកសារនូវករណីទាសករពលកម្មដោយបង្ខំដែលត្រូវបានវាយដំ រំលោភជាក្រុម និងចាក់សារឲ្យនៅក្នុងបន្ទប់តូច បង្អត់អាហារ និងសម្លាប់ ។ ជនរងគ្រោះដែលព្យាយាមរត់គេច ជាទូទៅត្រូវបានបង្ក្រាប វាយដំ និងបញ្ជូនត្រឡប់មកកាន់ទីកន្លែងវិញ ។ ប៉ុន្តែមានជនរងគ្រោះដោយទាសភាពភាគតិចប៉ុណ្ណោះដែលព្យាយាមរត់គេច ពីព្រោះម្ចាស់បំណុលប្រើប្រាស់នូវការបន្លាចនិងការបោកបញ្ឆោតដែលធ្វើឲ្យជនរងគ្រោះផុងខ្លួននៅក្នុងបន្ទប់ដែលចាក់សោរ ។

បច្ចេកទេសមួយដែលសាមញ្ញដើម្បីដាក់អន្ទាក់ពលករគឺបំណុលបោកបញ្ឆោត ។ ម្ចាស់បំណុលទាក់ទាញមនុស្សក្រីក្រឲ្យចូលទៅក្នុងទាសភាព ដោយផ្តល់នូវការបើកលុយតិចតួចជាមុនសម្រាប់ពលកម្ម ។ បន្ទាប់មក ម្ចាស់បំណុលធ្វើឲ្យទាសករមិនអាចសងប្រាក់វិញបាន ដោយបង្កើនការប្រាក់ដ៏ច្រើនទៅលើប្រាក់ដែលបើកឲ្យមុននោះ មិនបើកលុយឲ្យជនរងគ្រោះតាមការសន្យា និងហាមប្រាមជនរងគ្រោះមិនឲ្យទៅធ្វើការកន្លែងផ្សេង ។ បំណុលបោកបញ្ឆោតនេះអាចត្រូវបានផ្ទេរពីជំនាន់មួយទៅជំនាន់មួយ ។ យើងបានរកឃើញនូវគ្រួសារទាំងមូល(ពីជីដូនជីតា ទៅឪពុកម្ដាយ និងទៅកូន) ដែលត្រូវបានបង្ខំឲ្យធ្វើការអស់រយៈពេលជាច្រើនឆ្នាំបន្ទាប់ពីទទួលយកការបើកប្រាក់ជាមុនត្រឹមតែ ២០ ដុល្លារតែប៉ុណ្ណោះ ។

### អង្គការ IJM បានប្រយុទ្ធប្រឆាំងនឹងទាសភាពពលកម្មដោយបង្ខំនៅក្នុងប្រទេសឥណ្ឌា

នៅក្នុងឆ្នាំ ២០១៤ អង្គការ IJM នឹងបើកការិយាល័យថ្មីមួយទៀតនៅ Ghana ដែលមានកុមាររាប់ពាន់នាក់ត្រូវបានធ្វើជាទាសករនៅក្នុងឧស្សាហកម្មនេសាទ នៅតំបន់ទន្លេ Lake Volta ។

- ការជួយសង្គ្រោះជនរងគ្រោះ ៖ យើងបានរកឃើញមនុស្សដែលជាប់អន្ទាក់នៅក្នុងទាសភាព ធ្វើដៃគូជាមួយអាជ្ញាធរក្នុងស្រុកដើម្បីធ្វើប្រតិបត្តិការជួយសង្គ្រោះ ហើយធានាឲ្យជនរងគ្រោះនីមួយៗបានរួចខ្លួនដោយស្របច្បាប់និងទទួលបានការគាំទ្រពីរដ្ឋាភិបាល ។

- ការនាំយកឧក្រិដ្ឋជនឲ្យទទួលទោស ៖ យើងគាំទ្រដល់របាយការណ៍ប៉ូលិសដើម្បីប្តឹងម្ចាស់បំណុលឬជនល្មើសជួញដូរមនុស្ស និងគាំទ្រឲ្យមានការកាត់ទោសដល់ម្ចាស់ទាសករ ។

- ការស្តារនីតិសម្បទាដល់ជនរងគ្រោះ ៖ យើងបង្កើតជាផែនការថែទាំដល់បុគ្គលនីមួយៗដើម្បីឆ្លើយតបនឹងការប៉ះទង្គិចផ្លូវចិត្ត និងស្វែងរកការងារសមរម្យ និងផ្តល់ឱកាសឲ្យទទួលបានការអប់រំ ។

- ការពង្រឹងប្រព័ន្ធយុត្តិធម៌ ៖ យើងផ្តល់នូវការងារដឹកនាំជាគំរូសម្រាប់មន្ត្រីអនុវត្តន៍ច្បាប់មន្ត្រីរដ្ឋាភិបាល និងអង្គការជាដៃគូ ។ យើងក៏បានបង្កើតផងដែរនូវតម្រូវការសង្គម និងការតស៊ូមតិជាមួយថ្នាក់ដឹកនាំជាតិដើម្បីបញ្ឈប់ទាសភាពដែលជាការងារអាទិភាព ។

## ២. ការជួញដូរផ្លូវភេទ

ការជួញដូរផ្លូវភេទគឺជាទម្រង់នៃទាសករទាន់សម័យ ដែលបុគ្គលម្នាក់បង្ខំបុគ្គលផ្សេងទៀតឲ្យចូលទៅក្នុងពាណិជ្ជកម្មផ្លូវភេទ ឬការកេងប្រវ័ញ្ចកុមារនៅក្នុងពាណិជ្ជកម្មផ្លូវភេទ ។ វាគឺជាជំនួញនៃអំពើហិង្សាផ្លូវភេទ ។ សុបិន្តដ៏អាក្រក់នៃពេស្យាកម្មដោយបង្ខំបានបន្តជីវិត នៅពេលដែលអ្នកអនុវត្តន៍ច្បាប់មិនអាច ឬមិនការពារកុមារ ឬស្ត្រីដែលងាយរងគ្រោះ ។

- នៅទូទាំងពិភពលោក មានកុមារជិត ២លាននាក់ ត្រូវបានជួញដូរនៅក្នុងពាណិជ្ជកម្មផ្លូវភេទ[1]
- ការជួញដូរផ្លូវភេទផ្តល់ប្រាក់ចំណេញដ៏ច្រើនដល់ជនល្មើស ដែលមានតម្លៃទីផ្សារប្រហែល ៣២ កោដិដុល្លារនៃអំពើជួញដូរមនុស្ស ។[2]

ភាគច្រើននៃជនរងគ្រោះដោយអំពើជួញដូរមានប្រវត្តិជាអ្នកក្រីក្រ ។ ជាពិសេស ស្ត្រី និងកុមារដែលក្រីក្រងាយរងគ្រោះចំពោះការបោកប្រាស់របស់ជនល្មើសជួញដូរ ពីព្រោះតម្រូវការខ្លាំងផ្នែកសេដ្ឋកិច្ចដែលបង្ខំឲ្យពួកគេ (ឪពុកម្តាយ ឬអាណាព្យាបាល)មានឆន្ទៈទទួលយកនូវហានិភ័យដែលភាគច្រើនយល់ព្រមទទួលយកនូវការងារដែលផ្តល់ដោយជនល្មើស ឬសំណើឲ្យរៀបអាពាហ៍ពិពាហ៍ក្លែងក្លាយ ផ្លាស់ប្តូរទៅកាន់ទីតាំងផ្សេង ឬធ្វើអន្តោប្រវេសន៍ទៅកាន់ប្រទេសដទៃ ឬជឿថាជនរងគ្រោះផ្សេងក៏បានទទួលយកនូវសំណើទាំងនេះដែរ ដែលនេះគឺជាបច្ចេកទេសបោកប្រាស់

[1] UNICEF. State of the World's Children 2005.

[2] United Nations. "UNODC Launches global initiative to fight human trafficking."

ដាក់អន្ទាក់របស់ជនល្មើស ។

ពេលដែលត្រូវបានគេជួញដូរភ្លាម ជនរងគ្រោះដឹងខ្លួនឯងថាប្រឈមមុខនឹងអំពើហិង្សាដែលជាការគំរាមឥតឈប់ឈរ ។ បន្ថែមលើការរំលោភជាបន្តបន្ទាប់ កុមារ និងនីតិជនដែលត្រូវបានគេបង្ខំឲ្យចូលទៅក្នុងពាណិជ្ជកម្មផ្លូវភេទ គឺងាយរងគ្រោះចំពោះការធ្វើបាបផ្នែករាងកាយ ពីមេបន អ្នកទាក់ម៉ូយ និងអតិថិជន ។ នៅក្នុងករណីរបស់អង្គការ IJM ជនរងគ្រោះដែលរួចផុតពីការជួញដូរផ្លូវភេទ បានរៀបរាប់ពីទង្វើដែលត្រូវបានគេវាយដំជាមួយដំបងឈើ ដំបងដែក ឬខ្សែភ្លើង ការចាក់ថ្នាំញៀនណាកូទីក និងត្រូវបានបង្ខំឲ្យមើលគេធ្វើបាបផ្លូវកាយរបស់កូនខ្លួនឯង ។ ពួកគេប្រឈមមុខនឹងការឆ្លងជំងឺអេដស៍ និងជំងឺឆ្លងផ្លូវភេទផ្សេងទៀត ។

ទោះបីជាការជួញដូរផ្លូវភេទគឺជាឧក្រិដ្ឋកម្មកើតឡើងជាសាកលក៏ដោយ វាគឺជារឿងដែលគេដឹងជាទូទៅថាជាបញ្ហានៃប្រព័ន្ធយុត្តិធម៌អន់ថយ ដែលជនល្មើសដឹងខ្លួនឯងថា ពួកគេមិនទំនងប្រឈមមុខនឹងផលវិបាក ដែលកើតចេញពីការរកប្រាក់កម្រៃពីការបំពានផ្លូវភេទជារឿយរបស់ខ្លួនឡើយ ។ រឿងដែលល្អគឺថា ឧក្រិដ្ឋកម្មដែលប្រព្រឹត្តដោយជនល្មើសជួញដូរ មេបនឬបុគ្គលផ្សេងដែលរកប្រាក់កម្រៃដោយសារពេស្យាកម្មដោយបង្ខំ ខ្លាចរអាចំពោះចំណាត់ការរបស់អ្នកអនុវត្តន៍ច្បាប់ ។ នៅពេលដែលមានកាត់ទោសឲ្យជាប់ពន្ធនាគារ និងការរឹបអូសទ្រព្យសម្បត្តិយ៉ាងច្រើនគឺជនល្មើសលែងត្រូវការនូវប្រាក់ចំណេញដែលបានមកពីហានិភ័យទាំងអស់នេះ និងបានផ្លាស់ប្តូរទង្វើរបស់ខ្លួន ។

## អង្គការ IJM ប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរផ្លូវភេទនៅក្នុងតំបន់អាមេរិកឡាទីន អាស៊ីខាងត្បូង និងអាស៊ីអាគ្នេយ៍

- ការសង្គ្រោះជនរងគ្រោះ ៖ យើងបានរកឃើញនូវកុមារនិងនីតិជនដែលត្រូវបានគេបង្ខំឲ្យចូលទៅក្នុងឧស្សាហកម្មផ្លូវភេទ បានគាំទ្រប្រតិបត្តិការសង្គ្រោះរបស់អ្នកអនុវត្តន៍ច្បាប់អាជីព និងធ្វើឲ្យប្រាកដថា បុគ្គលទាំងអស់ រួមទាំងបុគ្គលដែលមិនត្រូវបានគេជួញដូរដែលអាចមានវត្តមានក្នុងពេលប្រតិបត្តិការ ត្រូវបានគេប្រព្រឹត្តដោយភាពថ្លៃថ្នូផងដែរ ។

- ការនាំយកឧក្រិដ្ឋជនឲ្យទទួលទោសតាមច្បាប់ ៖ យើងកសាងនូវករណីរឿងដ៏រឹងមាំប្រឆាំងនឹងជនល្មើសជួញដូរ មេបន និងជនល្មើសដទៃទៀត ព្រមទាំងគាំទ្រដល់ការកាត់ទោសផងដែរ ។

- ការស្តារនីតិសម្បទាជនដែលត្រូវបានជួយសង្គ្រោះ ៖ យើងបង្កើតនូវផែនការព្យាបាលដល់ជនដែលត្រូវបានសង្គ្រោះនូវការថែទាំដ៏ល្អ ដោយមានការឲ្យស្នាក់នៅ ការប្រឹក្សាពីជំងឺប៉ះទង្គិចផ្លូវចិត្ត និងការទទួលបានការអប់រំ និងការបណ្តុះបណ្តាលវិជ្ជាជីវៈ ។

- ការពង្រឹងប្រព័ន្ធយុត្តិធម៌ ៖ យើងផ្តល់នូវការបណ្តុះបណ្តាល និងការផ្តល់នូវការនាំមុខធ្វើការងារជាគំរូចំពោះអ្នកអនុវត្តន៍ច្បាប់ ចៅក្រម អ្នកព្យាបាល និងអ្នកអាជីព ព្រមទាំងការតស៊ូមតិសម្រាប់ការរីកចម្រើនដល់ប្រព័ន្ធយុត្តិធម៌ដែលនឹងធានាថា ករណីរបស់ខ្លួននឹងត្រូវបានដឹងឮ និងជនរងគ្រោះត្រូវបានការពារ ។

### ៣. អំពើហិង្សាផ្លូវភេទ

អំពើហិង្សាផ្លូវភេទជាជំងឺឆ្លងសាកលមួយ ដែលបន្សល់ទុកមនុស្សរាប់លាននាក់ ក្នុងពិភពលោកនូវភាពភ័យខ្លាចនៅក្នុងផ្ទះរបស់ខ្លួន សាលារៀន និងសង្កាត់ដែលខ្លួនរស់នៅ ។ អំពើហិង្សាអាចរាប់បញ្ចូលនូវការរំលោភ ការបៀតបៀន និងទម្រង់ផ្សេងទៀតនៃការបំពានផ្លូវភេទ ។ មនុស្សគ្រប់រូបអាចក្លាយជាជនរងគ្រោះដោយអំពើហិង្សានេះ ក៏ប៉ុន្តែទម្រង់នៃអំពើហិង្សានេះភាគច្រើនកើតឡើងជាញឹកញាប់ចំពោះស្ត្រីនិងកុមារី ជាពិសេសស្ត្រីនិងកុមារីដែលក្រីក្រហើយងាយរងគ្រោះ ។

- ស្ត្រីម្នាក់ក្នុងចំណោម៥នាក់ ត្រូវបានប៉ាន់ប្រមាណថា ជាជនរងគ្រោះដោយអំពើរំលោភ ឬប៉ុនប៉ងរំលោភនៅក្នុងមួយជីវិតរបស់ពួកគេ ។[3]
- នៅក្នុងប្រទេសដែលកំពុងអភិវឌ្ឍ សកម្មភាពប្រចាំថ្ងៃជាមូលដ្ឋាន ដូចជាធ្វើដំណើរតាមមធ្យោបាយដឹកជញ្ជូនសាធារណៈ ការប្រើបង្គន់សហគមន៍ ការដងទឹកនៅឆ្ងាយពីផ្ទះ អាចដាក់ក្មេងស្រីនិងស្ត្រីនៅក្នុងហានិភ័យនៃការបំពានផ្លូវភេទ ។[4]
- សាលារៀនគឺជាទីកន្លែងសាមញ្ញដែលមានអំពើហិង្សាផ្លូវភេទសម្រាប់ក្មេងស្រីដែលក្រីក្រ ហើយវាគឺជាហេតុផលទូទៅដែលក្មេងស្រីបោះបង់ការរៀនសូត្រ ។
- នៅក្នុងប្រទេសកំពុងអភិវឌ្ឍ ការគំរាមកំហែងនៃអំពើហិង្សាផ្លូវភេទគឺកើតមានជានិច្ច ។ ការសិក្សាជាច្រើនបង្ហាញថា កុមារភាគច្រើនក្លាយជាជនរងគ្រោះដោយ

[3] United Nations. "Unite to End Violence Against Women: Fact Sheet." (2008).

[4] United Nations Millennium Project "Taking Action: achieving gender equality and empowering women" P. 112

អំពើហិង្សាផ្លូវភេទនៅក្នុងទីកន្លែង ដែលពួកគេគិតថាជាទីកន្លែងមានសុវត្ថិភាព ដូចជានៅក្នុង សង្កាត់ ផ្ទះ ឬសាលារៀនរបស់ខ្លួន ។[5]

អ្នករួចផុតពីអំពើហិង្សាផ្លូវភេទ ប្រឈមមុខគ្រប់ទីកន្លែងនូវឧបសគ្គចំពោះយុត្តិធម៌ ប៉ុន្តែមាននូវផ្លូវរាំងស្ទះដែលធ្វើឲ្យអស់សង្ឃឹមនៅក្នុងប្រទេសកំពុងអភិវឌ្ឍ ។ ជនរងគ្រោះ ជាពិសេសកុមារ ជារឿយៗត្រូវបានស្ដីបន្ទោសសម្រាប់ការត្រូវគេរំលោភ ឬសកម្មភាពរបស់ខ្លួនអំពីការរំលោភដែលគេមិនអើពើ ឬពួកគេត្រូវបានគាបសង្កត់ឲ្យនៅស្ងៀម ដោយសារតែស្នាមទុរយសនៃការរំលោភបំពាន ។ ជនល្មើសអាចផ្ដល់នូវសំណងជាប្រាក់ចំពោះឪពុកម្ដាយរបស់ជនរងគ្រោះ ជាថ្នូរនឹងការមិនប្ដឹង ឬការឲ្យជនរងគ្រោះរៀបអាពាហ៍ពិពាហ៍ ដែលករណីទាំងនេះច្រើនកើតឡើងចំពោះគ្រួសារក្រីក្រដែលជីវភាពរស់នៅមានកង្វះខាតខ្លាំង ។

ប្រសិនបើប៉ូលិសជាអ្នកធ្វើរបាយការណ៍ ប៉ូលិសតាមមូលដ្ឋានគឺមិនទំនងនឹងស្វែងរក និងតាមចាប់ខ្លួនជនសង្ស័យ និងថែមទាំងមិនធ្វើការស៊ើបអង្កេតផ្នែកភស្ដុតាងឲ្យបានត្រឹមត្រូវនៅកន្លែងកើតហេតុ ។ ប្រសិនបើជនរងគ្រោះមានលទ្ធភាពប្ដឹងដល់តុលាការ ជនរងគ្រោះអាចត្រូវបានបង្ខំឲ្យធ្វើសក្ខីកម្មនៅចំពោះមុខជនល្មើសដែលរំលោភបំពានខ្លួន ។ ករណីរឿងជាច្រើនត្រូវចំណាយពេលវេលាជាច្រើនឆ្នាំដើម្បីឈានដល់ការសម្រេច ហើយតម្រូវឲ្យមានការសួរនាំជាច្រើនលើកច្រើនសារ និងការកោះហៅរបស់តុលាការជាញឹកញាប់ ដែលធ្វើឲ្យប៉ះទង្គិចផ្លូវចិត្តយ៉ាងធ្ងន់ធ្ងរ ។ សម្រាប់ហេតុផលទាំងនេះ ករណីដែលត្រូវបានរាយការណ៍ភាគច្រើនមិនបានឈានដល់ដំណាក់កាលកាត់ក្ដីឡើយ ។ នៅពេលដែលគ្មានផលវិបាកពិតប្រាកដប៉ះពាល់ដល់ជនរំលោភបំពាន និងឧក្រិដ្ឋជន កុមារនិងស្ត្រីដែលងាយរងគ្រោះមិនបានទទួលសំណងអ្វីឡើយ ។

## អង្គការ IJM ប្រយុទ្ធប្រឆាំងអំពើហិង្សាផ្លូវភេទលើកុមារនៅក្នុងតំបន់អាហ្វ្រិក អាម៉េរិកឡាទីន និងអាស៊ីអាគ្នេយ៍

- ការជួយសង្គ្រោះជនរងគ្រោះ ៖ យើងធ្វើឲ្យប្រាកដថា កុមារមានសុវត្ថិភាពរួចផុតពីជនល្មើស (រួមទាំងការផ្លាស់ប្ដូរទីលំនៅ ប្រសិនបើកុមារអាចមានគ្រោះថ្នាក់ក្នុងពេលស្នាក់នៅឯផ្ទះរបស់ខ្លួន) ។

[5] Shireen J. Jejeebhoy and Sarah Bott. Non-Consensual Sexual Experiences of Young People: A Review of the Evidence from Developing Countries

- នាំយកឧក្រិដ្ឋជនឲ្យទទួលខុសត្រូវចំពោះអំពើរបស់ខ្លួន ៖ យើងស៊ើបអង្កេតករណីជាច្រើន ជួយឲ្យមានការចាប់ខ្លួនឧក្រិដ្ឋជន និងគាំទ្រការកាត់ទោសដល់ជនល្មើស និងជនរំលោភបំពានផ្សេងទៀត ។

- ការស្តារនីតិសម្បទាដល់ជនរងគ្រោះ ៖ យើងផ្តល់នូវការប្រឹក្សាផ្នែកការប៉ះទង្គិចផ្លូវចិត្ត ជួយជនរងគ្រោះឲ្យត្រៀមខ្លួនក្នុងការផ្តល់នូវការពិតនៅក្នុងតុលាការ និងគាំទ្រគ្រួសារពួកគេ ដើម្បីឲ្យកុមារអាចជាសះស្បើយនៅក្នុងបរិស្ថានដែលមានលំនឹងនិងសុវត្ថិភាព ។

- ការពង្រឹងប្រព័ន្ធយុត្តិធម៌ ៖ យើងផ្តល់ការបណ្តុះបណ្តាល និងការនាំមុខធ្វើការងារជាគំរូដល់មន្ត្រីអនុវត្តន៍ច្បាប់ ចៅក្រម អ្នកអាជីពជាពេទ្យនិងអ្នកអាជីពផ្សេងទៀត ព្រមទាំងការតស៊ូមតិសម្រាប់ការកែទម្រង់នៃដំណើរការរឿងក្តីនៅតុលាការ ដើម្បីការពារកុមារ ។

## ៤. ការរឹបអូសយកទ្រព្យសម្បត្តិ

- – Dr. Hamid Rashid, United Nations មានប្រសាសន៍ថា "ដោយមានការកំហិត និងភាពគ្មានសុវត្ថិភាពចំពោះសិទ្ធិលើកម្មសិទ្ធិដីធ្លី ទោះបីជាអាចមានលទ្ធភាពក៏ដោយ វាគឺជារឿងលំបាកសម្រាប់ជនក្រីក្រដើម្បីយកឈ្នះលើភាពក្រីក្រ ។" សម្រាប់គ្រួសារក្រីក្រ ផ្ទះសំបែងនិងដីមួយកន្លែងគឺជាប្រភពតែមួយគត់សម្រាប់ការស្នាក់នៅ ម្ហូបអាហារ និងប្រាក់ចំណូល ។ ប៉ុន្តែសម្រាប់មនុស្សជាច្រើនដែលរស់នៅក្នុងភាពក្រីក្រ ជាពិសេសស្ត្រីមេម៉ាយនិងកុមារកំព្រា មូលដ្ឋានតម្រូវការទាំងនេះមិនមានសុវត្ថិភាព សម្រាប់ពួកគេឡើយ ។ ញាតិមិត្ត ឬអ្នកជិតខាងដែលមានឥទ្ធិពលជាញឹកញាប់លួចប្លន់ទ្រព្យសម្បត្តិទាំងនេះដោយប្រើអំពើហិង្សា ឬការឆបោក ហើយគ្មានការព្រួយបារម្ភចំពោះផលវិបាកនោះឡើយ ។
- ជាពិសេស ស្ត្រីមេម៉ាយងាយរងគ្រោះចំពោះការឈ្លានពានយកទ្រព្យសម្បត្តិ ។ មានស្ត្រីមេម៉ាយច្រើនជាង ១១៥ លាននាក់ ដែលរស់នៅក្នុងភាពអត់ឃ្លានយ៉ាងខ្លាំងនៅក្នុងពិភពលោក ហើយក្នុងនោះមានកុមារ ០,៥ កោដិនាក់ ដែលពឹងផ្អែកក្នុងការរស់នៅរបស់ខ្លួនលើស្ត្រីមេម៉ាយទាំងនោះ ។[6]

[6] Sylvia B. Ondimba. "The World Must Support Its Widows." The Guardian. June 23, 2011. Web. Available online.

- នៅត្រឹមឆ្នាំ ២០២០ ប្រជាជនក្រីក្រ ១.៥ កោដិ ដែលរស់នៅជាយក្រុង នឹងរស់នៅទីកន្លែងគ្មានសុវត្ថិភាព និងកន្លែងចាក់សម្រាមដោយគ្មានសិទ្ធិលើកម្មសិទ្ធិទ្រព្យសម្បត្តិរបស់ខ្លួន ។[7]
- នៅក្នុងប្រទេសកំពុងអភិវឌ្ឍ ស្ត្រីជាច្រើនប្រឈមមុខនឹងហានិភ័យចំពោះការឈ្លានពានយកទ្រព្យសម្បត្តិ ជាពិសេសនៅក្នុងស្ថានភាពដែលត្រូវបានចាត់ទុកជាទ្រព្យគ្មានតម្លៃ អន់ ឬគ្រាន់តែជារបស់អ្វីមួយ ។

នៅក្នុងប្រទេសអាហ្វ្រិក ការឈ្លានពានយកដីធ្លីជាញឹកញាប់កើតឡើងបន្ទាប់ពីមរណភាពរបស់ស្វាមីឬឪពុក នៅពេលដែលស្ត្រីមេម៉ាយ និងកូនកំព្រាងាយទទួលភាពរងគ្រោះ ។ ភ្លាមៗញាតិមិត្ត និងអ្នកជិតខាងចាប់ផ្តើមបែងចែកនូវផ្ទះសំបែងនិងដីធ្លី ដកហូតរបស់កម្មសិទ្ធិ ដោយធ្វើឲ្យស្ត្រីមេម៉ាយ និងកូនកំព្រាគ្មានផ្ទះរស់នៅ ។

ប្រសិនបើស្ត្រីមេម៉ាយបដិសេធមិនចាកចេញ នាងនិងកូនរបស់នាងអាចត្រូវបានបណ្តេញចេញដោយគេប្រើអំពើហិង្សា ។ ស្ត្រីនិងកុមារជាច្រើនដែលយើងជួយ រាយការណ៍ថាពួកគេត្រូវបានគេគំរាមកំហែងដោយប្រើកាំបិត និងការបំពានផ្លូវកាយ ។ មានករណីខ្លះ ផ្ទះរបស់ពួកគេត្រូវបានដុតបំផ្លាញដោយជនល្មើសដែលមានបំណងធ្វើឲ្យពួកគេមិនអាចរស់នៅលើដីធ្លីនោះបាន ។ ជាញឹកញាប់ ជនល្មើសដែលឈ្លានពានយកទ្រព្យសម្បត្តិមានចំណងជាប់ទាក់ទងនឹងជនរងគ្រោះ ដូចនេះប៉ូលិសអាចទាត់ចោលករណីនោះ ហើយចាត់ទុកថាជាបញ្ហាក្នុងគ្រួសារ ។ ទីភ្នាក់ងារអនុវត្តន៍ច្បាប់ខ្វះខាតការបណ្តុះបណ្តាល និងធនធានដើម្បីដោះស្រាយនូវបញ្ហាទាំងនេះ ។ ដោយគ្មានការជួយពីប្រព័ន្ធយុត្តិធម៌ ជនដែលនៅមានជីវិតក្លាយជាជនរងគ្រោះដែលត្រូវតស៊ូនឹងការឈ្លានពានយកទ្រព្យសម្បត្តិ ។ ស្ត្រីទាំងនោះអាចត្រូវបានបង្ខំឲ្យស្វែងរកទីលំនៅកន្លែងផ្សេងដែលមានគ្រោះថ្នាក់ឬងាយរងគ្រោះចំពោះការកេងប្រវ័ញ្ចនៅពេលដែលនាងកំពុងស្វែងរកទីកន្លែងស្នាក់នៅ ។ ពួកគេអាចគ្មានលទ្ធភាពទទួលបានម្ហូបអាហារ ការថែទាំព្យាបាល ឬតម្រូវការចាំបាច់ផ្សេងទៀត សម្រាប់កូនៗនិងខ្លួនឯង ។

[7] UN-HABITAT. "Secure Land Rights for All."

## អង្គការ IJM ការពារស្ត្រីមេម៉ាយ កុមារកំព្រា និងជនងាយរងគ្រោះផ្សេងទៀត ពីការឈ្លានពានយកទ្រព្យសម្បត្តិ នៅក្នុងប្រទេស អ៊ូហ្គាន់ដា និងហ្សាំប៊ី

- ការជួយជនរងគ្រោះ ៖ យើងជួយដល់ស្ត្រីមេម៉ាយ និងកុមារកំព្រាឲ្យទទួលបានផ្ទះសំបែងរបស់ខ្លួនវិញនិងការពារប្រឆាំងនឹងការគំរាមប្រើអំពើហិង្សាដែលកើតមានឡើងចំពោះពួកគេ ។

- នាំយកឧក្រិដ្ឋជនឲ្យទទួលទោស ៖ យើងកសាងនូវករណីបទល្មើសព្រហ្មទណ្ឌប្រឆាំងនឹងជនល្មើស ដែលប្រើអំពើហិង្សា ការបំភិតបំភ័យឬការឆបោក ។

- ការស្តារនីតិសម្បទាដល់ជនរងគ្រោះ ៖ យើងផ្តល់នូវការថែទាំព្យាបាលជាបន្ទាន់ និងការប្រឹក្សាយោបល់ ដើម្បីធានាថា កុមារអាចទៅសាលារៀនបាន ទទួលបានអ្វីដែលជាការចាំបាច់ជួយស្ត្រីឲ្យចាប់ផ្តើមគម្រោងដែលអាចរកប្រាក់ចំណូលបាន ។

- ការពង្រឹងប្រព័ន្ធយុត្តិធម៌ ៖ យើងផ្តល់ការបណ្តុះបណ្តាល និងការនាំមុខធ្វើការងារជាគំរូដល់ប៉ូលិស និងអ្នកដឹកនាំតាមមូលដ្ឋានស្តីពីការអនុវត្តដ៏មានប្រសិទ្ធភាពនូវច្បាប់ប្រឆាំងនឹងការឈ្លានពានយកទ្រព្យសម្បត្តិ ។

### ៥. ការរំលោភបំពានអំណាចរបស់ប៉ូលិស

- ការរំលោភបំពានអំណាចដោយប៉ូលិសគឺជាបញ្ហាដ៏ខ្លាំងក្លានិងជាសាកល ៖ ប្រជាជនក្រីក្ររាប់លាននាក់នៅក្នុងប្រទេសដែលកំពុងអភិវឌ្ឍ ត្រូវបានរំលោភបំពានដោយប៉ូលិសខិលខូចដែលគំរាមយកសំណូក និងប្រើអំពើព្រៃផ្សៃធ្វើបាបប្រជាជនស្លូតត្រង់ឬឃុំខ្លួនដោយបំពានមុនការកាត់ក្តី ។
- នៅក្នុងប្រទេសជាច្រើនដែលកំពុងអភិវឌ្ឍ ឪពុកម្តាយត្រូវតែបង្រៀនកូនចៅរបស់ខ្លួនឲ្យគេចចេញឲ្យឆ្ងាយពីប៉ូលិស ដើម្បីសុវត្ថិភាព ជាជាងបង្ហាត់កូនចៅរបស់ខ្លួនឲ្យរត់ទៅរកប៉ូលិសទោះបីពួកគេមានបញ្ហាក៏ដោយ ។
- នៅក្នុងឯកសារ Voices of the Poor, The World Bank ៖ ប្រជាជនក្រីក្រចាត់ទុកប៉ូលិសគឺជាភ្នាក់ងារគាបសង្កត់ មិនមែនអ្នកការពារនោះទេ ។ ម្តងហើយម្តងទៀត ប្រជាជនក្រីក្រនិយាយថា យុត្តិធម៌និងការការពាររបស់ប៉ូលិសមានតែសម្រាប់ជំនួញអ្នកមាន និងអ្នកមានខ្នងបង្អែកតែប៉ុណ្ណោះ ។

## អង្គការ IJM ប្រយុទ្ធប្រឆាំងនឹងការរំលោភបំពានអំណាចដោយប៉ូលិស
## នៅក្នុងទីក្រុងណាយរ៉ូប៊ី ប្រទេសកេនយ៉ា

- ជួយសង្គ្រោះជនរងគ្រោះ ៖ យើងកំណត់អត្តសញ្ញាណបុរសនិងស្ត្រីសុចរិតដែលត្រូវបានគេឃុំខ្លួនដោយគ្មានភស្តុតាង ស៊ើបអង្កេតលើករណី ដើម្បីបង្ហាញភស្តុតាងពីភាពសុចរិតរបស់ពួកគេ និងតំណាង នៅក្នុងតុលាការដើម្បីឲ្យពួកគេទទួលបាននូវសេរីភាព និងការរួចខ្លួនពីការចោទប្រកាន់ខុសមកលើពួកគេ ។

- នាំយកឧក្រិដ្ឋជនមកកាត់ទោស ៖ យើងសហការជាមួយទីភ្នាក់ងារស៊ើបអង្កេត របស់រដ្ឋាភិបាល ដើម្បីចោទប្រកាន់ដល់ប៉ូលិសដែលរំលោភបំពានអំណាច ។

- ស្តារនីតិសម្បទាដល់ជនរងគ្រោះ ៖ យើងផ្តល់ការថែទាំជាប្រចាំដល់ជនរងគ្រោះ និងគ្រួសាររបស់ពួកគេ នៅក្នុងអំឡុងពេលដែលពួកគេជាប់ឃុំឃាំង និងអភិវឌ្ឍនូវផែនការមាតុភូមិនិវត្តន៍សម្រាប់ភាពមានសេរីភាព ។

- ពង្រឹងប្រព័ន្ធយុត្តិធម៌ ៖ យើងផ្តល់នូវការបណ្តុះបណ្តាល និងការនាំមុខធ្វើការងារជាគំរូសម្រាប់ប៉ូលិសនិងមន្ត្រីផ្សេងទៀត និងគាំទ្រដល់រដ្ឋាភិបាលក្នុងការពង្រឹងនូវការអនុវត្តច្បាប់ដែលការពារប្រជាជនស្លូតត្រង់ ។

### ៦. ការរំលោភបំពានសិទ្ធិប្រជាពលរដ្ឋ

- អ្នកស្រី ណយ ជាសមាជិកនៃកុលសម្ព័ន្ធព្រៃភ្នំនៅភាគខាងជើងប្រទេសថៃ ដែលបានតស៊ូប្រឆាំងសម្រាប់ភាពមានសញ្ជាតិរបស់ខ្លួនអស់រយៈពេលជិតមួយទស្សវត្សរ៍មុននឹងនាងបានជួយអង្គការ IJM បាននិយាយថា "អ្នកមិនអាចនឹកស្មានដល់ជីវិតដែលគ្មានកាតអត្តសញ្ញាណសម្គាល់ខ្លួននៅក្នុងប្រទេសថៃ ។"
- ជាសាកល ប្រជាជនប្រហែល ១២ លាននាក់ ត្រូវបានប៉ាន់ប្រមាណថាគ្មានរដ្ឋ និងសញ្ជាតិរបស់ខ្លួន ។ គ្មានសញ្ជាតិមានន័យថាគ្មានប្រទេសដែលជាស្រុកកំណើតរបស់ខ្លួន ។ គ្មានប្រព័ន្ធយុត្តិធម៌ការពារខ្លួន និងគ្មានការធានាណាមួយថា កូនចៅរបស់អ្នកនឹងអាចទៅសាលារៀនបាន ឬអាចស្វែងរកការងារដែលបានប្រាក់កម្រៃសមរម្យនោះឡើយ ។

- មានប្រជាជនប្រមាណ ១២ លាននាក់គ្មានរដ្ឋរបស់ខ្លួននៅក្នុងពិភពលោក ហើយក្នុងនោះមានប្រមាណ ២០% រស់នៅក្នុងប្រទេសថៃ ។[8]
- មានប្រហែល ១២ក្រុមសម្ព័ន្ធព្រៃភ្នំ (ជនជាតិភាគតិច) ដែលរស់នៅក្នុងតំបន់ខ្ពង់រាបខាងជើងនិងខាងលិចប្រទេសថៃ គឺប្រហែល ៦០០ ពាន់ ទៅ ១លាននាក់ ។[9]
- ភាពគ្មានសញ្ជាតិគឺជាកត្តាហានិភ័យចម្បង សម្រាប់ស្ត្រី និងក្មេងស្រីជនជាតិភាគតិចនៅក្នុងប្រទេសថៃ ដែលត្រូវបានគេជួញដូរ ឬកេងប្រវ័ញ្ច ។[10]

នៅក្នុងតំបន់ព្រៃភ្នំនៃប្រទេសអាស៊ានជាច្រើន រួមមានប្រទេសថៃ ភូមា វៀតណាម ឡាវ និងចិន ក្រុមជនជាតិភាគតិចដែលជាក្រុមកុលសម្ព័ន្ធព្រៃភ្នំបានរស់នៅក្នុងស្រុកភូមិរបស់ខ្លួនអស់ជាច្រើនជំនាន់មកហើយ ។ ព្រំដែនប្រទេសបានផ្លាស់ប្តូរ និងច្បាប់ត្រូវបានអភិវឌ្ឍទៅតាមការរីកចម្រើន ប៉ុន្តែក្រុមកុលសម្ព័ន្ធទាំងនោះមិនត្រូវបានគេចាប់អារម្មណ៍ឡើយ ។

សម្រាប់ជនជាតិភាគតិចរាប់ពាន់នាក់ ប្រទេសថៃគឺជាប្រទេសកំណើតរបស់ខ្លួន និងមានសិទ្ធិតាមផ្លូវច្បាប់ទទួលបានសញ្ជាតិថៃ ។ តែទោះជាយ៉ាងណាក៏ដោយ ដោយមានបទប្បញ្ញត្តិស្មុគស្មាញ កង្វះធនធាន ភាពព្រងើយកន្តើយនិងការរើសអើងរបស់រដ្ឋាភិបាលបានរារាំងពួកគេមិនឲ្យទទួលបានឯកសារកំណត់អត្តសញ្ញាណ និងស្ថានភាពចុះឈ្មោះដើម្បីទទួលបានសញ្ជាតិរបស់ខ្លួន ។ ដោយគ្មានឯកសារទាំងនេះ ពួកគេមិនត្រូវបានទទួលស្គាល់ថាជាប្រជាជននៃប្រទេសរបស់ខ្លួនឡើយ ដែលមានន័យថា ជាប្រជាជនគ្មានរដ្ឋ ។

បើគ្មានឯកសារបញ្ជាក់ពីសញ្ជាតិដែលជាសិទ្ធិស្របច្បាប់របស់ខ្លួន ជនជាតិថៃភាគតិចទាំងនេះអាចត្រូវបានបដិសេធការថែទាំនៅឯមន្ទីរពេទ្យ ហាមឃាត់ពីកម្មសិទ្ធលើដីធ្លី និងត្រូវចាប់ខ្លួនសម្រាប់ការធ្វើដំណើរចេញក្រៅពីភូមិស្រុករបស់ខ្លួន ។ គ្មានការធានាថាកូនរបស់ខ្លួនទទួលបានសិទ្ធិចូលរៀន ឬការងារដែលមានកម្រៃសមរម្យ ។ ដោយគ្មានការការពារពីប្រព័ន្ធយុត្តិធម៌ ស្ត្រីនិងក្មេងស្រីទាំងនេះងាយទទួលរងនូវអំពើហិង្សា ដូចជាការរំលោភផ្លូវភេទ និងការជួញដូរមនុស្ស ។

[8] IRIN. “In Brief: 12 million people still stateless”

[9] Physicians for Human Rights. "No Status: Migration, Trafficking & Exploitation of Women in Thailand"

[10] "Searching for Identity," Yindee Lertharoenchok; Step by Step, UN Interagency Project Newsletter: Fourth Quarter, 2001, Issue 5.

អង្គការ IJM បានជួយជនជាតិថៃភាគតិចរាប់ពាន់នាក់ឲ្យទទួលបានឯកសារបញ្ជាក់សញ្ជាតិរបស់ខ្លួន ដែលជាសិទ្ធិមួយដែលធានាដល់ពួកគេនូវសេរីភាពក្នុងការធ្វើដំណើរក្នុងប្រទេសដោយគ្មានការភ័យខ្លាចដែលត្រូវគេចាប់ខ្លួន ជាសិទ្ធិមួយក្នុងការទទួលបានការងារធ្វើ និងអប់រំដល់កូនចៅរបស់ខ្លួន និងជាសិទ្ធិទទួលបានការការពារដ៏ពេញលេញតាមផ្លូវច្បាប់ ។ អង្គការ IJM បានជួយដល់ជនជាតិទាំងនេះ ក្នុងដំណើរការបំពេញសំណុំបែបបទដ៏ស្មុគស្មាញ និងការតស៊ូមតិតំណាងឲ្យពួកគេជាហូរហែ ដើម្បីដំណើរការនូវករណីរបស់ពួកគេទៅកាន់ការិយាល័យផ្តល់សញ្ជាតិរបស់រដ្ឋាភិបាលដែលមានការងារដ៏ច្រើន ។

# សេចក្តីសន្និដ្ឋាន

អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិបានធ្វើសកម្មភាពជាច្រើន ក្នុងការជួយសង្គ្រោះជនរងគ្រោះដោយអំពើជួញដូរមនុស្ស ជាច្រើននាក់ ដោយផ្តល់នូវការស្តារនីតិសម្បទា ជាមួយនឹងអង្គការដៃគូដែលមានសេវាកម្មថែទាំនៅក្នុងមណ្ឌលថែទាំរបស់ខ្លួន ដូចជា ការបណ្តុះបណ្តាលវិជ្ជាជីវៈ រយៈពេលខ្លី រយៈពេលវែង ការជួយស្វែងរកការងារធ្វើ ជាដើម ។

ទន្ទឹមនឹងនេះ អង្គការ IJM ក៏បានសហការធ្វើការជាមួយនគរបាលជាតិកម្ពុជា ជាពិសេសនគរបាលប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ក្នុងប្រតិបត្តិការជួយសង្គ្រោះជនរងគ្រោះប្រកបដោយជោគជ័យជាច្រើនករណី ដែលក្នុងនោះក៏មានការចាប់បញ្ជូនជនល្មើសជួញដូរមនុស្សទៅកាន់តុលាការ ដើម្បីទទួលទោសតាមច្បាប់ ។

លើសពីនេះ អង្គការ IJM ក៏បានសហការជាមួយអគ្គស្នងការនគរបាលជាតិ ក្នុងការបណ្តុះបណ្តាល ផ្តល់ធនធាន សម្ភារៈ ថវិកា និងបច្ចេកទេសស៊ើបអង្កេតដល់នគរបាលប្រឆាំងការជួញដូរមនុស្សនៅតាមបណ្តាខេត្តទាំង ២៤ និងរាជធានី ដែលជាការចូលរួមចំណែកក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស ។

ក្រៅពីនេះ អង្គការ IJM ក៏បានធ្វើការបណ្តុះបណ្តាលដល់ស្ថាប័នអយ្យការ និងចៅក្រមផងដែរ នូវច្បាប់នានាដែលទាក់ទងនឹងអំពើជួញដូរមនុស្ស ។

## អនុសាសន៍

ទោះបីជាអង្គការ IJM ជាអង្គការអន្តរជាតិតូច ក៏ប៉ុន្តែអង្គការ IJM មានគោលបំណង និងទិសដៅជាក់លាក់ក្នុងការងាររបស់ខ្លួន ដើម្បីប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស ស្តារនីតិសម្បទាដល់ជនរងគ្រោះ និងជួយឲ្យប្រព័ន្ធយុត្តិធម៌សាធារណៈកម្ពុជា (នគរបាលប្រឆាំងការជួញដូរមនុស្សព្រះរាជអាជ្ញា និងមន្ត្រីនៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា) ធ្វើការប្រកបដោយប្រសិទ្ធភាព និងមានភាពប្រសើរឡើងនៅក្នុងការបំពេញភារកិច្ច ក៏ដូចការអនុវត្តច្បាប់ប្រកបដោយភាពជោគជ័យ ។

ក្នុងនាមយើងជាអ្នកសិក្សាស្វែងយល់ វាជារឿងល្អដែលគួរយល់ដឹងពីអង្គការ IJM ទូទាំងពិភពលោក ក៏ដូចជាអង្គការ IJM ប្រចាំនៅកម្ពុជា ដែលធ្វើកិច្ចសហប្រតិបត្តិការជាមួយមន្ត្រីអនុវត្តច្បាប់គ្រប់ជាន់ថ្នាក់ ក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស ជាពិសេសអំពើធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ និងជាពិសេសសម្រាប់ការសិក្សាស្រាវជ្រាវតទៅមុខទៀត ។

រាល់សកម្មភាពល្មើសច្បាប់ទាក់ទងនឹងអំពើជួញដូរមនុស្ស អំពើហិង្សាផ្លូវភេទ ឬអំពើធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ ដែលអ្នកជួបប្រទះ ឬសង្ស័យ អ្នកអាចទាក់ទងរាយការណ៍ដល់នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ឬអង្គការ IJM ប្រចាំនៅកម្ពុជាដើម្បីចូលរួមជាចំណែកក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្សនៅកម្ពុជា ។

ទាំងអស់នេះគឺជាសកម្មភាពមនុស្សធម៌ដែលអង្គការ IJM បានធ្វើកន្លងមក ក្នុងការរួមចំណែកបំបាត់អំពើជួញដូរមនុស្ស ទាសភាព ពលកម្មដោយបង្ខំ ការឈ្លានពានយកទ្រព្យសម្បត្តិការទទួលបានសញ្ជាតិ និងអំពើហិង្សា និងផ្តល់ការបណ្តុះបណ្តាលដល់មន្ត្រីអនុវត្តន៍ច្បាប់ ដឹកនាំធ្វើការងារជាគំរូ ដើម្បីធ្វើឲ្យប្រសើរឡើងនូវប្រព័ន្ធយុត្តិធម៌សាធារណៈដែលពិតជាការពារប្រជាជនក្រីក្រ ជាពិសេសស្ត្រី និងកុមារ ឲ្យទទួលបានសិទ្ធិក្នុងការរស់នៅ សុវត្ថិភាព សន្តិសុខ ការអភិវឌ្ឍបែបប្រជាធិបតេយ្យ ភាពថ្លៃថ្នូ និងសុភមង្គល ។

## **ឯកសារយោង**

- ឯកសាររបស់អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ
- www.ijm.org.